**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ :...១៧៧...បទ.គល

ថ្ងៃ ច័ន្ទ ៣កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ជួសជុល ផ្លាស់ប្តូរ និង ថែទាំឧបករណ៍ Router ដើម្បីពង្រីកសមត្ថភាព
## នៃល្បឿនអ៊ិនធឺណិតរហូតដល់២០Gbps នៅអគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមជូនដំណឹងចំពោះក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកតបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា ៖ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ជ្រើសរើស "អ្នកទទួលការ" ជួសជុល ផ្លាស់ប្តូរ និងថែទាំឧបករណ៍ Router ដើម្បីពង្រីកសមត្ថភាពនៃល្បឿនអ៊ិនធឺណិតរហូតដល់២០Gbps នៅអគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំសំណើដេញថ្លៃសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានអាសយដ្ឋានអគារលេខ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី ថ្ងៃទី..៣១.. ខែ..ឧសភា..ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរសព្ទទាក់ទងលេខ ០២៣ ៤២៧ ៥០៧)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង..១៥:៣០..រសៀល ថ្ងៃទី..៧....ខែ..កក្កដា..ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង..១៥:៣០..រសៀល ថ្ងៃទី..៧..... ខែ..កក្កដា.. ឆ្នាំ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃ បានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានបន្ថែមដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**សារ៉ាក់ ខាន់**

ចម្លងជូន :
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកសារ កាលប្បវត្តិ

**បានពិនិត្យត្រឹមត្រូវ**
**អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ**